# គោលការណ៍ណែនាំរបស់ អង្គការសហប្រជាជាតិ ស្ដីពីការដោះស្រាយ និង ការប្រឆាំងនឹងពាក្យស្អប់ខ្ពើមទាក់ទងនឹង ជំងឺកូវីដ-១៩

១១ ឧសភា ២០២០

United Nations

# ១. សេចក្តីផ្តើម

ជំងឺកូវីដ-១៩ បានបង្ហាញឱ្យឃើញពីសាមគ្គីភាពគ្នាដ៏ច្រើនលើសលប់រវាងប្រជាជាតិ និងសហគមន៍ទាំងឡាយដែលធ្វើការរួមគ្នា ដើម្បីដោះស្រាយផលប៉ះពាល់ និងបញ្ហាប្រឈមផ្សេងៗ។ ជាអកុសល ជំងឺរាតត្បាតនេះបានបង្កឱ្យមានរលកថ្មីនៃពាក្យសម្តីស្អប់ខ្ពើម និងការរើសអើង។ "ពាក្យសម្តីស្អប់ខ្ពើមទាក់ទងនឹងជំងឺកូវីដ-១៩" រាប់បញ្ចូលការបញ្ចេញមតិរិះគន់ផ្សេងៗគ្នាជាច្រើនទៅលើបុគ្គល និងក្រុមមនុស្សមួយចំនួន ដែលបានលេចចេញ ឬបានធ្វើឱ្យកាន់តែធ្ងន់ធ្ងរឡើង ដោយសារតែការផ្ទុះឡើងនៃមេរោគកូរ៉ូណាថ្មី ដោយរាប់ចាប់ពីការទម្លាក់កំហុសដាក់អ្នកដទៃ ផ្ទត់គំនិតចាស់កំរិលការមាក់ងាយ និងការប្រើប្រាស់ភាសាអាសគ្រាម ខឹងស្អប់ស្ត្រី ប្រកាន់ជាតិសាសន៍ ស្អប់ខ្ពើមជនបរទេស ស្អប់ខ្ពើមអ្នកកាន់សាសនាអ៊ីស្លាម ឬភាសាប្រឆាំងនឹងក្រុមជាតិសាសន៍ជាដើម។ ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងបញ្ហានេះ គឺការផ្សព្វផ្សាយ "ព័ត៌មានមិនពិត" ឬ " ព័ត៌មានមិនត្រឹមត្រូវ" ទាក់ទងនឹងជំងឺកូវីដ-១៩[1]។

ចាប់តាំងពីកើតមានជំងឺនេះ បុគ្គលទាំងឡាយដែលមានរាងរៅដូចជាជនជាតិចិន ឬអាស៊ី ឬសមាជិកក្រុមភាគតិចជាតិពន្ធុនិងសាសនា ទេសន្តរប្រវេសន៍ និងជនបរទេស ត្រូវបានគេស្តីបន្ទោស និងត្រូវបានគេមួលបង្កាច់ថាជាអ្នកចម្លងមេរោគ។ ក្នុងករណីខ្លះ បញ្ហានេះបានកើតចេញពីព័ត៌មានមិនពិត និងពាក្យចចាមអារាម ទោះជាដូច្នេះក្តី មានករណីច្រើនទៀតដែលបណ្តាលមកពីពាក្យសម្តីស្អប់ខ្ពើមទាក់ទងទៅនឹងជំងឺកូវីដ-១៩ ត្រូវបានគេប្រើប្រាស់ ដើម្បីកំណត់គោលដៅទៅលើប្រជាជនដែលបានបាត់បង់ឱកាសរួចហើយក៏ត្រូវបានគេរាយការណ៍ផងដែរ។ ទ្រឹស្តីនៃការសមគំនិត និយាយសំដៅការរីករាលដាលនៃមេរោគនេះ ដល់ជនជាតិជ្វីហ្វ អ្នកកាន់សាសនាអ៊ីស្លាម គ្រីស្តសាសនិក ក្រុមជនជាតិភាគតិចបាហៃ ឬក្រុមជនជាតិភាគតិចផ្សេងទៀត បានដុតបង្កាត់ឱ្យមានពាក្យសម្តីរើសអើងទៅលើបុគ្គលទាំងនេះ ក្នុងករណីខ្លះ បណ្តាលឱ្យមានបទល្មើសស្អប់ខ្ពើម ឬការរើសអើងទៅលើពួកគេ ក្នុងការឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ ។ ក្នុងករណីខ្លះ អ្នកសារព័ត៌មាន[2] អ្នកផ្តល់ព័ត៌មាន អ្នកជំនាញវេជ្ជសាស្ត្រ និងសុខភាព អ្នកការពារសិទ្ធិមនុស្ស និងអ្នកកសាងសន្តិភាពក៏បាន និងកំពុងទទួលរងការវាយប្រហារដោយខុសច្បាប់ ដោយសារតែការងាររបស់ពួកគេ ក្នុងការដោះស្រាយ ឬរាយការណ៍អំពីជំងឺនេះផងដែរ។ បាតុភូតនៃពាក្យសម្តីស្អប់ខ្ពើមទាក់ទងនឹងជំងឺកូវីដ-១៩ មានសន្ទុះលឿនទៅមុខ តាមរយៈប្រព័ន្ធផ្សព្វផ្សាយធម្មតា និងតាមរយៈបណ្តាញសង្គមអនឡាញ និងវេទិកាបច្ចេកវិទ្យាផ្សេងៗ។ ទោះជាតាមធម្មតា បាតុភូតផ្សព្វផ្សាយពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតក្តី ក៏ផលវិបាករបស់វាមានលក្ខណៈធ្ងន់ធ្ងរបំផុត នៅពេលដែលមេដឹកនាំនយោបាយ មន្ត្រីសាធារណៈ អ្នកដឹកនាំសាសនា និងអ្នកមានឥទ្ធិពលផ្សេងទៀត យកទៅធ្វើការឃោសនា ឬនៅពេលដែលវាក្លាយជាផ្នែកមួយនៃ

[1] https://en.unesco.org/sites/default/files/disinfodemic_dissecting_responses_covid19_disinformation.pdf

[2] A/HRC/44/49, paras 34 – 40.

កិច្ចប្រឹងប្រែងរួមគ្នា ដោយបុគ្គល ឬក្រុមមនុស្ស ដើម្បីផ្សព្វផ្សាយពីការខឹងស្អប់ ឬ អំពើហិង្សាដោយការញុះញង់។ ពាក្យសម្តីស្អប់ខ្ពើមទាក់ទងនឹងជំងឺកូវីដ-១៩ មានផលប៉ះពាល់ធ្ងន់ធ្ងរ ទាំងក្នុងរយៈពេលខ្លី និងក្នុងរយៈពេលវែង។ វាធ្វើឱ្យបុគ្គលជាគោលដៅរិតតែងាយរងគ្រោះថែមទៀត ទៅនឹងអំពើហិង្សា ងាយនឹងធ្វើឱ្យពួកគេប្រឈមនឹងការផាត់ចេញខាងនយោបាយ និងសង្គម ការដាក់ឱ្យនៅដាច់ដោយឡែក និងការមាក់ងាយ រារាំងពួកគេមិនឱ្យបញ្ចេញមតិផ្ទាល់ខ្លួន និងការចូលរួមជជែកដេញដោលជាសាធារណៈ និងរារាំងពួកគេមិនឱ្យទទួលបានកិច្ចគាំពារផ្នែកវេជ្ជសាស្ត្រ និងសេវាសំខាន់ៗដទៃផ្សេងទៀត។ ការធ្វើដូច្នេះ វារិតតែធ្វើឱ្យមានផលប៉ះពាល់មិនសមាមាត្រនៃជំងឺនេះ ទៅលើសហគមន៍ជាក់លាក់និងធ្វើឱ្យកាន់តែធ្ងន់ធ្ងរថែមទៀត ដល់វិសមភាពសង្គម និងសេដ្ឋកិច្ចដែលមានស្រាប់ ជាកត្តាជំរុញឱ្យមានសកម្មភាពជ្រុលនិយមហិង្សា ទន្ទឹមនឹងនេះ វាធ្វើឱ្យអន្តរាយដល់ឯកភាពសង្គម សាមគ្គីភាព និងការជឿទុកចិត្តគ្នាដែលចាំបាច់ ដើម្បីដោះស្រាយការរីករាលដាលនៃមេរោគ។

វាក៏អាចបង្កឱ្យមានភាពរឹករវក្នុងសង្គម និងអំពើហិង្សារវាងក្រុមនិងក្រុមមនុស្សផងដែរ ដែលអាចជម្រុញលក្ខខណ្ឌអំណោយផលដល់ការបង្កើតជម្លោះ និងឧក្រិដ្ឋកម្មឃោរឃៅ។[3] ដូច្នេះ ពាក្យសម្តីស្អប់ខ្ពើមទាក់ទងនឹងជំងឺកូវីដ-១៩ អាចបង្កការគំរាមកំហែងដល់ការអនុវត្តសិទ្ធិមនុស្ស ការអភិវឌ្ឍប្រកបដោយចីរភាព និងសន្តិភាព និងសន្តិសុខអន្តរជាតិ។

ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងជាសកល ដើម្បីឆ្លើយតបនឹងជំងឺរាតត្បាត សហគមន៍អន្តរជាតិចាំបាច់ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ និងបន្តធ្វើការថ្កោលទោសដាច់ខាត ចំពោះពាក្យសម្តីស្អប់ខ្ពើមទាក់ទងនឹងជំងឺកូវីដ-១៩ ដោយលើកកំពស់បរិយាបន្ន ធ្វើការដោយសាមគ្គីភាពគ្នា និងឈរលើមូលដ្ឋានច្បាប់សិទ្ធិមនុស្សអន្តរជាតិ ជាពិសេស សេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ និងសិទ្ធិខាងសមភាព និងការមិនរើសអើង។

ខណៈពេលដែលរដ្ឋជាសមាជិកទាំងឡាយ មានទំនួលខុសត្រូវចម្បង ចំពោះពាក្យសម្តីស្អប់ខ្ពើមទាក់ទងទៅនឹងជំងឺកូវីដ-១៩ តួអង្គដទៃទៀត ជាពិសេស ក្រុមហ៊ុនបច្ចេកវិទ្យា និងបណ្តាញសង្គម ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងសង្គមស៊ីវិល ក៏មានតួនាទីសំខាន់ផងដែរ។ ប្រព័ន្ធអង្គការសហប្រជាជាតិដើរតួសំខាន់ ជាពិសេស ក្នុងការគាំទ្រដល់រដ្ឋ និងតួអង្គដទៃទៀត ដើម្បីបង្កើត និងអនុវត្តវិធានការទាំងឡាយ ដែលស្របតាមគោលការណ៍សិទ្ធិមនុស្ស ដើម្បីដោះស្រាយការពាក្យសម្តីស្អប់ខ្ពើមទាក់ទងនឹងជំងឺកូវីដ-១៩ ។ ដូចដែលអគ្គលេខាធិការអង្គការសហប្រជាជាតិបានគូសបញ្ជាក់នៅពេលប្រកាសជាផ្លូវការ នូវសេចក្តីសង្ខេបគោលនយោបាយ "ជំងឺកូវីដ-១៩ និងសិទ្ធិមនុស្ស៖ យើងទាំងអស់គ្នានៅទីនេះរួមគ្នា " នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០ សិទ្ធិមនុស្ស ត្រូវតែជាកិច្ចខិតខំប្រឹងប្រែង "ជួរមុខ និងជាស្នូល" ក្នុងការឆ្លើយតប និងការជាសះស្បើយឡើងវិញ" ទាក់ទងនឹងជំងឺកូវីដ-១៩ ដែលជា"

[3] អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

វិបត្តិអន្តរជាតិដ៏ធំបំផុត ជាច្រើនជំនាន់៎ ។ គោលការណ៍ណែនាំនេះ ដាក់ចេញជាអនុសាសន៍ជាច្រើនដល់តួអង្គផ្សេងៗ សម្រាប់ដោះស្រាយ និងប្រយុទ្ធប្រឆាំងនឹងពាក្យសម្តីស្អប់ខ្ពើមទាក់ទងនឹងជំងឺកូវីដ-១៩ ។ គោលការណ៍ណែនាំនេះ បង្កើត និងបំពេញបន្ថែមលើយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់អ.ស.ប ស្តីពីពាក្យសម្តីស្អប់ខ្ពើម។

## ២. អនុសាសន៍

### ដល់នាយកដ្ឋាន ទីភ្នាក់ងារ មូលនិធិ និងកម្មវិធីផ្សេងៗ របស់អង្គការសហប្រជាជាតិ

- បន្តគូសបញ្ជាក់ថា ការលើកកំពស់សេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ គឺជាមូលដ្ឋានគ្រឹះនៃសង្គមទាំងឡាយ ដោយផ្អែកលើនីតិរដ្ឋប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។
- ថ្កោលទោសចំពោះពាក្យសម្តីស្អប់ខ្ពើមខ្ពើមទាក់ទងទៅនឹងជំងឺកូវីដ-១៩ បង្ហាញពីសាមគ្គីភាពជាមួយជនរងគ្រោះដោយជំងឺនេះ និងគាំទ្រដល់អ្នកដែលតវ៉ា និងប្រឆាំងនឹងការបញ្ចេញមតិបែបនេះ
- ទទួលស្គាល់ តាមដាន ប្រមូលទិន្នន័យ និងវិភាគនិន្នាការស្តីពីពាក្យសម្តីស្អប់ខ្ពើមទាក់ទងនឹងជំងឺកូវីដ-១៩ នៅថ្នាក់ជាតិ និងកម្រិតពិភពលោក ដើម្បីគាំទ្រការឆ្លើយតបប្រកបដោយប្រសិទ្ធភាព។
- កោះប្រជុំតួអង្គពាក់ព័ន្ធ - រួមមានរដ្ឋសមាជិក អង្គការតំបន់ ប្រព័ន្ធផ្សព្វផ្សាយ និងវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គមអង្គការសង្គមស៊ីវិល និងតួអង្គសុឆន្ទៈដទៃទៀត ក្នុងកា បង្កើតយុទ្ធសាស្ត្រ ដើម្បីកំណត់ ដោះស្រាយ និងប្រឆាំងនឹងពាក្យសម្តីស្អប់ខ្ពើមពាក់ព័ន្ធនឹងជំងឺកូវីដ-១៩ នៅថ្នាក់ជាតិ និងកម្រិតពិភពលោក ដោយអនុលោមតាមយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់អង្គការសហប្រជាជាតិ ស្តីពីពាក្យសម្តីស្អប់ខ្ពើម

## ដល់រដ្ឋសមាជិកនានា

• លើកកម្ពស់សេរីភាព ក្នុងការស្វែងរក ទទួល និងចែកចាយព័ត៌មាន ដែលជាមូលដ្ឋានគ្រឹះនៃការកសាងទំនុកចិត្ត ក្នុងវិធានការផ្សេងៗដែលបានធ្វើឡើង ដើម្បីទប់ទល់នឹងជំងឺនេះ

• ធ្វើឱ្យប្រាកដថា វិធានការ ច្បាប់ ឬគោលនយោបាយបន្ទាន់ ឬពិសេសណាមួយ ដែលបានធ្វើឡើង ដើម្បីឆ្លើយតបទៅនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ត្រូវបានបញ្ជាក់ និងអនុវត្តស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដូចមានចែងក្នុងសេចក្តីសង្ខេបគោលនយោបាយរបស់អគ្គលេខាធិការ ស្តីពីជំងឺកូវីដ-១៩ និងសិទ្ធិមនុស្ស និងកំណត់គោលការណ៍ណែនាំ ដោយការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស[4]

• ដោះស្រាយ និងប្រឆាំងជាសាធារណៈ និងយ៉ាងឆាប់រហ័ស នឹងពាក្យសម្តីស្អប់ខ្ពើមពាក់ព័ន្ធនឹងជំងឺកូវីដ-១៩ តាមរយៈ៖

> អនុវត្តវិធានការឆ្លើយតបនឹងវិបត្តិដែលមានទំនាក់ទំនងរឹងមាំ ដើម្បីធានាឱ្យសារឆ្លើយឆ្លងគ្នាមានលក្ខណៈច្បាស់លាស់ នៅក្នុងដំណាក់កាលឆ្លើយតបនៃជំងឺរាតត្បាត និងកាត់បន្ថយផលប៉ះពាល់នៃវិបត្តិនេះ ទៅលើការផ្សារភ្ជាប់សង្គម និងភាពធន់របស់សហគមន៍។

> ធានាថាព័ត៌មានត្រឹមត្រូវ និងបានផ្ទៀងផ្ទាត់ អំពីជំងឺរាតត្បាត ត្រូវបានផ្សព្វផ្សាយជាទៀងទាត់ ដោយការផ្ញើសារជាសាធារណៈយ៉ាងរឹងមាំ ប្រឆាំងនឹងពាក្យសម្តីស្អប់ខ្ពើមទាក់ទងនឹងជំងឺកូវីដ-១៩ ការផ្សព្វផ្សាយព័ត៌មានមិនពិតការផ្សព្វផ្សាយព័ត៌មានមិនត្រឹមត្រូវ និងទ្រឹស្តីនៃការសមគំនិត។

> គាំទ្រប្រព័ន្ធដែលមានតម្លាភាព ដែលអាចប្រើប្រាស់បាន និងឯករាជ្យ សម្រាប់តាមឃ្លាំមើលពាក្យសម្តីស្អប់ខ្ពើម ទាក់ទងនឹងជំងឺកូវីដ-១៩

> គាំទ្រការផលិត និងការផ្សព្វផ្សាយឯករាជ្យនៃនិទានកថាដែលជាផលប្រយោជន៍សាធារណៈ ត្រឹមត្រូវ និងមានលក្ខណៈវិជ្ជាជីវៈ

> អំពីការតស៊ូ និងចម្រុះភាពពេញលេញ នៃបុគ្គលដែលរងផលប៉ះពាល់ដោយជំងឺកូវីដ-១៩ និងអំពីបទពិសោធន៍របស់អ្នកទាំងឡាយ ដែលងាយរងគ្រោះបំផុត ពីពាក្យសម្តីស្អប់ខ្ពើមទាក់ទងនឹងជំងឺកូវីដ-១៩ ។

• ធានាថារាល់ទំនាក់ទំនងសាធារណៈរបស់មន្ត្រីរដ្ឋ ជាពិសេស សេចក្តីថ្លែងការណ៍ ដោយសមាជិកជាន់ខ្ពស់នៃរដ្ឋាភិបាល ទាក់ទងនឹងជំងឺកូវីដ-១៩៖

> អាចប្រើប្រាស់បាន ត្រឹមត្រូវ ពេញលេញ អាចទុកចិត្ត បានផ្អែកលើភស្តុតាង មានតម្លាភាព ដែលអាចរកបាននៅក្នុងភាសាទាំងអស់ ដែលនិយាយនៅក្នុងចំណោមប្រជាជន ហើយត្រូវបានចែកចាយបានទាន់ពេលវេលា។

> មិនត្រូវធ្វើការស្តីបន្ទោស ឬដាក់ការទទួលខុសត្រូវចំពោះការកើតឡើងមាន ឬការរីករាលដាលនៃមេរោគនេះទៅលើសហគមន៍ ឬក្រុមណាមួយឡើយ

> ជំរុញបរិយាប័ន និងបង្ហាញសមាជិកពីសហគមន៍

[4] SG Policy Brief ‘COVID-19 and Human Rights: We are all in this together’ https://www.un.org/sites/un2.un.org/files/un_policy_brief_on_ human_rights_and_covid_23_april_2020.pdf; OHCHR, Emergency Measures and COVID-19: Guidance, 27 April 2020 https://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=25828&LangID=E

ចម្រុះ ដែលរងផលប៉ះពាល់ពីមេរោគ និងធ្វើការរួមគ្នា ដើម្បីបង្ការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩

• ធានាថាការឆ្លើយតបតាមផ្លូវច្បាប់ ចំពោះពាក្យសម្តីស្អប់ខ្ពើម ត្រូវមានតុល្យភាពយ៉ាងត្រឹមត្រូវជាមួយនឹងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិយោបល់ និងសិទ្ធិទទួលបានព័ត៌មាន រួមទាំងលំហូរសេរីនៃព័ត៌មានវិទ្យាសាស្ត្រ និងគំនិត ស្តីពីជំងឺកូវីដ-១៩ រាប់ទាំង តាមរយៈ៖

> ធានាថា រាល់ការកម្រិតកំណត់លើសេរីភាពក្នុងការបញ្ចេញមតិយោបល់ ត្រូវបានកំណត់ដោយច្បាប់ និងចាំបាច់និងសមាមាត្រ ដើម្បីគោរពសិទ្ធិ ឬកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ ឬការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ ឬសុខភាព ឬសុជីវធម៌សាធារណៈ។

> ការចៀសវាងការដាក់ចេញនូវវិធានការត្រួតពិនិត្យលើការនិយាយស្តី លើកលែងតែវិធានការទាំងនោះបំពេញតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ

ដោយសារវិធានការបែបនេះ អាចបណ្តាលឱ្យមានការកម្រិតកំណត់លើសិទ្ធិទទួលបានព័ត៌មានសំខាន់ សម្រាប់សុខភាពសាធារណៈ[5]

> ធានាសុវត្ថិភាពរបស់អ្នកសារព័ត៌មាន និងការការពារប្រភពផ្សេងៗ ដែលរួមមាន អ្នកកាសែត និងអ្នកផ្តល់ព័ត៌មាន ដែលបានលើកឡើងពីកង្វល់ស្របច្បាប់ អំពីជំងឺកូវីដ-១៩ និងការឆ្លើយតបចំពោះកង្វល់នោះ មិនត្រូវប្រឈមនឹងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ការដាក់ទោសទណ្ឌផ្នែករដ្ឋប្បវេណី ការបំភិតបំភ័យ ឬការយាយីឡើយ។

> ដោះលែងអ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស និងសកម្មជនសិទ្ធិមនុស្ស ដែលជាប់ឃុំឃាំងដោយខុស ឬដោយបំពាន រួមទាំង អ្នកដែលជាប់ពន្ធនាគារដោយសារការងារពាក់ព័ន្ធនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ។

> ជៀសវាងការយកករណីជំងឺកូវីដ-១៩ មកធ្វើជាលេស ដើម្បីរឹតត្បិតដោយខុសច្បាប់ ដល់សិទ្ធិរបស់សាធារណជនក្នុងការទទួលបានព័ត៌មាន និងសេរីភាពខាងប្រព័ន្ធផ្សព្វផ្សាយ ។

> ដកបញ្ហាបិទអ៊ីនធឺណិត និងការរឹតត្បិតលើសិទ្ធិទទួលបានព័ត៌មាន តាមអនឡាញ ជៀសវាងការបិទ ឬការរឹតត្បិតសិទ្ធិប្រើប្រាស់អ៊ីនធឺណិត និងចាត់វិធានការដ៏សកម្ម ដើម្បីលើកកំពស់សិទ្ធិប្រើប្រាស់អ៊ីនធឺណិត រួមទាំង តាមរយៈការផ្តល់លទ្ធភាពប្រើប្រាស់ដោយឥតគិតថ្លៃ ជាពិសេស ដល់ក្រុមងាយរងគ្រោះ ឬក្រុមដែលបាត់បង់ឱកាស។

> អនុវត្តឱ្យបានរឹងមាំនូវច្បាប់ស្តីពីសេរីភាពខាងព័ត៌មាន ដើម្បីធានាថា បុគ្គលគ្រប់រូប ជាពិសេស អ្នកសារព័ត៌មានមានសិទ្ធិទទួលបានព័ត៌មាន[6]

• ធានាថាការអប់រំ និងការបណ្តុះបណ្តាល ជាពិសេសនៅតាមសាលារៀន រួមទាំងតាមរយៈវេទិកាអនឡាញ លើកឡើងពីពាក្យសម្តីស្អប់ខ្ពើមទាក់ទងនឹងជំងឺកូវីដ-១៩ ការផ្សាយព័ត៌មានមិនពិត និងការផ្សាយព័ត៌មានមិនត្រឹមត្រូវ ដោយជំរុញលើក

[5]https://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=25729&LangID=E

[6]https://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=25729&LangID=E

ទឹកចិត្តឱ្យមានការគិតគូរពិចារណាឱ្យបានល្អិតល្អន់ ជំនាញខាងសង្គមនិងអារម្មណ៍ និងការចូលរួមប្រកបដោយការទទួលខុសត្រូវ តាមរយៈការអប់រំពលរដ្ឋជាសកល[7] និងការអប់រំសិទ្ធិមនុស្ស។

• ធានាថាសិទ្ធិរបស់អ្នកដែលជាគោលដៅដោយពាក្យសម្ដីស្អប់ខ្ពើមទាក់ទងនឹងជំងឺកូវីដ-១៩ ត្រូវបានលើកកំពស់រាប់ទាំង ដោយៈ

> ធានាថាការចោទប្រកាន់អំពីពាក្យសម្ដីស្អប់ខ្ពើមដែលអាចជាការញុះញង់ឱ្យមានការរើសអើង អរិយភាព ឬអំពើហិង្សាត្រូវបានស៊ើបអង្កេតដោយឯករាជ្យ ហើយជនល្មើសត្រូវទទួលខុសត្រូវ ចំពោះមុខច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

## ដល់ប្រព័ន្ធផ្សព្វផ្សាយ និងក្រុមហ៊ុនបច្ចេកវិទ្យា

• ធានាថា គោលនយោបាយរបស់ប្រព័ន្ធផ្សព្វផ្សាយ និងក្រុមហ៊ុនបច្ចេកវិទ្យា ទាក់ទងនឹងពាក្យសម្ដីស្អប់ខ្ពើម រាប់ទាំងពាក្យសម្ដីស្អប់ខ្ពើមពាក់ព័ន្ធនឹង ជំងឺកូវីដ-១៩ នៅលើវេទិការបស់គេ ៖

> មានភាពច្បាស់លាស់ ជាក់លាក់ និងត្រូវបានដាក់ចេញតាមមធ្យោបាយដែលអាចចូលទៅមើលបាន មានតម្លាភាព និងអាចយល់បានគ្រប់ជ្រុងជ្រោយ

> ត្រូវបានបង្កើតឡើង និងអនុវត្ត ស្របតាមបទដ្ឋានច្បាប់សិទ្ធិមនុស្សអន្តរជាតិ

> មានការវាយតម្លៃអំពីបរិបទសង្គម និងនយោបាយ ស្ថានភាព និងចេតនារបស់វាគ្មិន ខ្លឹមសារ និងវិសាលភាពនៃការផ្សព្វផ្សាយ ក៏ដូចជា ភាពអាចកើតមានគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ និងសាធារណជនផងដែរ។[8]

> ពាក់ព័ន្ធនឹងសហគមន៍ដែលរងផលប៉ះពាល់ខ្លាំងបំផុត ដោយមាតិកា ដែលគេស្គាល់ថាជា ពាក្យសម្ដីស្អប់ខ្ពើម នៅក្នុងការអភិវឌ្ឍឧបករណ៍ដ៏មានប្រសិទ្ធភាព ដើម្បីដោះស្រាយការបង្កគ្រោះថ្នាក់ដែលកើតមាននៅលើវេទិកា

> ផ្ដោតលើការជ្រើសរើស មាតិកា ដើម្បីធានាថា អ្នកប្រើប្រាស់អាចទទួលព័ត៌មាន ពីសារព័ត៌មានបានយ៉ាងងាយស្រួល ថាជាព័ត៌មានបានផ្ទៀងផ្ទាត់ដែលចែករំលែក ដើម្បីផលប្រយោជន៍សាធារណៈ

> ផ្ដល់ការគាំទ្រផ្នែកហិរញ្ញវត្ថុបន្ថែមទៀត ដល់បណ្ដាញត្រួតពិនិត្យការពិត សារព័ត៌មានឯករាជ្យ និងយុទ្ធនាការផ្សព្វផ្សាយចំណេះដឹងអំពីប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន

> ចៀសវាងជឿខ្លាំងពេកលើស្វ័យប្រវត្តិភាព ជាពិសេស សម្រាប់ការកាត់បន្ថយនូវមាតិកាដែលចាំបាច់ត្រូវពង្រីកដំណើរការពិនិត្យឡើងវិញរបស់មនុស្ស[9]

• តាមដានការផ្សព្វផ្សាយពាក្យសម្ដីស្អប់ខ្ពើមទាក់ទងនឹងជំងឺកូវីដ-១៩ នៅលើវេទិការបស់គេ

---

[7] https://en.unesco.org/themes/gced

[8] A/HRC/22/17/Add.4; https://www.ohchr.org/EN/Issues/FreedomOpinion/Articles19-20/Pages/Index.aspx

[9]https://en.unesco.org/sites/default/files/disinfodemic_dissecting_responses_covid19_disinformation.pdf

វាយតម្លៃពីរបៀបដែលវិធីសាស្ត្រឆ្លើយតបមានឥទ្ធិពលលើសិទ្ធិមនុស្សរបស់អ្នកប្រើប្រាស់របស់ខ្លួន និងធ្វើឱ្យព័ត៌មាននោះអាចទទួលបានជាសាធារណៈ

- បញ្ឈប់ពាក្យសម្ដីស្អប់ខ្ពើម ទាក់ទងនឹងជំងឺ-១៩ នៅពេលវាទាក់ទងនឹងការញុះញង់ឱ្យមានអរិយភាពការរើសអើង ឬអំពើហិង្សា ស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ
- ធានាថា ទាក់ទងទៅនឹងសកម្មភាពមិនល្អណាមួយប្រឆាំងនឹងពាក្យសម្ដីស្អប់ខ្ពើម ទាក់ទងនឹងជំងឺកូវីដ-១៩ មានដំណើរការត្រឹមត្រូវ រាប់ទាំងការជូនដំណឹងដល់អ្នកប្រើប្រាស់នៅពេលមានសកម្មភាពបែបនេះ និងផ្ដល់ឱកាសប្ដឹងសាទុក្ខ។
- សហការជាមួយភាគីពាក់ព័ន្ធ ជាពិសេស អង្គការសហប្រជាជាតិ រួមមាន អង្គការសុខភាពពិភពលោក ក្រសួងសុខាភិបាល និងក្រសួងអប់រំ ព្រមទាំង អាជ្ញាធរទាំងឡាយ ភ្នាក់ងារត្រួតពិនិត្យឯករាជ្យ អង្គការសង្គមស៊ីវិល និងក្រុមដែលរងផលប៉ះពាល់ ដើម្បីបង្កើត និងលើកកម្ពស់វិធីសាស្ត្រ និងយុទ្ធនាការទាំងឡាយ ក្នុងការដើម្បីដោះស្រាយ និងប្រឆាំងនឹងពាក្យសម្ដីស្អប់ខ្ពើមខ្ពើមទាក់ទងនឹងជំងឺកូវីដ-១៩ ការផ្ដល់ព័ត៌មានមិនពិត និងការផ្សាយព័ត៌មានមិនត្រឹមត្រូវ នៅលើវេទិការបស់ពួកគេ (ដូចជា ការអប់រំ ការរាយការណ៍និងការបណ្ដុះបណ្ដាល)

## ដល់ប្រព័ន្ធផ្សព្វផ្សាយ

- រាយការណ៍ប្រកបដោយបុរេសកម្ម និងវិជ្ជាជីវៈស្ដីពីសន្ទរកថាខឹងស្អប់ ពាក់ព័ន្ធនឹងជំងឺកូវីដ-១៩ ការផ្ដល់ព័ត៌មានមិនពិត ការផ្សាយព័ត៌មានមិនត្រឹមត្រូវ និងការរើសអើង មិនថាធ្វើឡើងដោយរដ្ឋ ឬស្ថាប័នមិនមែនរដ្ឋក្ដី
- គាំទ្រដល់ប្រព័ន្ធនៃការគ្រប់គ្រងខ្លួនឯងប្រកបដោយប្រសិទ្ធភាព (ដូចជា ស្ថាប័នថ្នាក់ជាតិសម្រាប់បណ្ដឹងតវ៉ាពាក់ព័ន្ធនឹងសារព័ត៌មាន និងអ្នកទទួលស៊ើបអង្កេតបណ្ដឹង ឬនិពន្ធនាយកសាធារណៈនៅតាមកន្លែងផ្សាយព័ត៌មាននីមួយៗ) ដើម្បីធានាថាសិទ្ធិកែតម្រូវ ឬឆ្លើយតបត្រូវបានអនុវត្ត ដើម្បីដោះស្រាយសេចក្ដីរាយការណ៍មានលក្ខណៈរើសអើងនៅក្នុងបរិបទនៃការផ្ទុះឡើង ជំងឺកូវីដ-១៩
- ប្រកាន់ខ្ជាប់នូវបទដ្ឋានសីលធម៌ និងវិជ្ជាជីវៈខ្ពស់បំផុត នៅពេលធ្វើរបាយការណ៍ស្ដីពីជំងឺកូវីដ-១៩ រាប់ទាំងការធ្វើសេចក្ដីរាយការណ៍អំពីការរាតត្បាតជំងឺកូវីដ-១៩ ឲ្យបានត្រឹមត្រូវ និងមិន លំអៀងដោយប្រើការត្រួតពិនិត្យការពិត ជៀសវាងការនិយាយរើសអើង និងដោយមិនចាំបាច់យោងទៅលើកត្តាទាំងឡាយ ដូចជា ពូជសាសន៍, ជាតិពិន្ទុ, សញ្ជាតិ ឬសាសនាឡើយ

—

4 A/HRC/22/17/Add.4; https://www.ohchr.org/EN/Issues/FreedomOpinion/Articles19-20/Pages/Index.aspx

5 https://en.unesco.org/sites/default/files/disinfodemic_dissecting_responses_covid19_disinformation.pdf

## ដល់សង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងទៀត

• ឥស្សរជនដែលមានឥទ្ធិពលនៅក្នុងសង្គម - រួមមាន មេដឹកនាំសាសនា តួអង្គជំនឿ មេដឹកនាំសហជីព មេដឹកនាំអង្គការមិនមែនរដ្ឋាភិបាល អ្នកដឹកនាំយុវជន ឥស្សរជនសាធារណៈ និងអ្នកមានឥទ្ធិពលទាំងឡាយ គួរនិយាយយ៉ាងសកម្មជាសាធារណៈប្រឆាំងនឹងពាក្យសម្តីស្អប់ខ្ពើម ទាក់ទងនឹងជំងឺកូវីដ-១៩ ការផ្តល់ព័ត៌មានមិនពិត ការផ្សព្វផ្សាយព័ត៌មានមិនត្រឹមត្រូវ និងទ្រឹស្តីពីការឃុបឃិត បង្ហាញពីសាមគ្គីភាពជាមួយអ្នកដែលត្រូវបានគេកំណត់ជាគោលដៅ ដោយការផ្សព្វផ្សាយព័ត៌មានបែបនោះ និងបំពងសំឡេងនូវសារទាំងឡាយ ដែលជួយកាត់បន្ថយការរើសអើង និងការមាក់ងាយ

• ស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ អង្គការសង្គមស៊ីវិល គួរតែសហការជាមួយភាគីពាក់ព័ន្ធរួមមាន រដ្ឋាភិបាល អង្គការសហប្រជាជាតិ អង្គការប្រចាំតំបន់ ប្រព័ន្ធផ្សព្វផ្សាយសង្គម និងក្រុមហ៊ុនបច្ចេកវិទ្យា អ្នកសារព័ត៌មាន និងស្ថាប័នសិក្សា និងអ្នកជំនាញ លើគំនិតផ្តួចផ្តើមដើម្បី

> តាមដាន និងរាយការណ៍អំពីលក្ខណៈ ទំហំ និងផលប៉ះពាល់នៃពាក្យសម្តីស្អប់ខ្ពើម ទាក់ទងនឹងជំងឺកូវីដ-១៩ ក៏ដូចជា វិធានការណ៍ផ្លូវច្បាប់ និងគោលនយោបាយ ដែលមានគោលបំណង ដើម្បីដោះស្រាយការបង្ហាញចេញនូវព័ត៌មានបែបនោះ។

> បង្កើតការឆ្លើយតបពាក់ព័ន្ធនឹងសហគមន៍ដែលរងផលប៉ះពាល់ខ្លាំងបំផុត (ឧទាហរណ៍ យុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយសង្គម)

# ៣. សេចក្តីសន្និដ្ឋាន

ការរាតត្បាតជំងឺកូវីដ-១៩ បានបំពងសំឡេងនៃការព្រួយបារម្ភដែលកំពុងតែកើតមាន ទាក់ទងនឹងការរីករាលដាល និងការប្រើប្រាស់ពាក្យសម្តីខឹងស្អប់ទូទាំងពិភពលោក។ វាក៏បានបង្កើតក្រុមងាយរងគ្រោះថ្មីដែលត្រូវបានគេកំណត់គោលដៅ ដោយពាក្យសម្តីស្អប់ខ្ពើម ។ ធានាថាពាក្យសម្តីស្អប់ខ្ពើម ត្រូវបានដោះស្រាយ និងប្រយុទ្ធប្រឆាំងយ៉ាងមានប្រសិទ្ធភាព ទាំងនៅថ្នាក់ជាតិ និងកម្រិតសកល នឹងជួយកែលម្អការឆ្លើយតបរបស់យើងចំពោះជំងឺរាតត្បាតក្នុងរយៈពេលខ្លី។ វាក៏នឹងផ្តល់ឱ្យយើងនូវឱកាសដើម្បី "កសាងឡើងវិញឲ្យបានល្អប្រសើរ" ដោយធ្វើការដោះស្រាយបុព្វហេតុនៃបាតុភូត នៅក្នុងសង្គមរបស់យើង តាមរយៈការលើកកម្ពស់ការរួមបញ្ចូលសាមគ្គីភាព និងមនុស្សជាតិរួមរបស់យើង។